# MIIS

ប្រព័ន្ធព័ត៌មានចាក់ថ្នាំបង្ការរដ្ឋ Massachusetts

## ព្រឹត្តិបត្រព័ត៌មានសម្រាប់ឪពុកម្តាយនិងអ្នកជំងឺ



MIIS គឺជាប្រព័ន្ធទូទាំងរដ្ឋថ្មីមួយ ដើម្បីតាមដានកំណត់ត្រាចាក់ថ្នាំបង្ការសម្រាប់អ្នកនិងគ្រួសារអ្នក។ កំណត់ត្រាទាំងនេះរៀបរាប់អំពីការចាក់វ៉ាក់សាំង (ចាក់ថ្នាំ) ដែលអ្នកនិងកូនរបស់អ្នកទទួលបាន ដើម្បីការការពារប្រឆាំងនឹងជំងឺកញ្ជ្រឹល អុតស្វាយ តេតាណូស និងជំងឺផ្សេងទៀត។ គោលដៅគឺដើម្បីធ្វើឲ្យប្រាកដថាមនុស្សគ្រប់រូបនៅក្នុងរដ្ឋ Massachusetts ទទួលបានព័ត៌មានថ្មីៗអំពីការចាក់ថ្នាំរបស់ពួកគេ និងឲ្យប្រាដថាកំណត់ត្រារបស់អ្នកអាចស្វែងរកបាននៅពេលអ្នកត្រូវការពួកវា ដូចជានៅពេលដែលកូនរបស់អ្នកចូលសាលា នៅពេលដែលអ្នកត្រូវការជំនួយវេជ្ជសាស្ត្រសង្គ្រោះបន្ទាន់ ឬនៅពេលដែលអ្នកផ្លាស់ប្តូរអ្នកផ្តល់សេវាថែទាំសុខភាព។

### តើ MIIS ជាអ្វី?

- ប្រព័ន្ធដំណើរការដោយកុំព្យូទ័រ ដែលប្រមូលនិងរក្សាទុកព័ត៌មានចាក់ថ្នាំបង្ការមូលដ្ឋានសម្រាប់ប្រជាពលរដ្ឋដែលរស់នៅក្នុងរដ្ឋ Massachusetts។
- ប្រព័ន្ធសុវត្ថិភាពនិងរក្សាការសម្ងាត់តាមដែលច្បាប់រដ្ឋ Massachusetts បានតម្រូវ។
- ប្រព័ន្ធមួយដែលមានផ្តល់ជូនដល់មនុស្សគ្រប់វ័យ មិនត្រឹមតែផ្តល់ជូនកុមារនោះទេ។

### តើវានឹងជួយខ្ញុំដូចម្តេច?

MIIS៖

- ជួយឲ្យអ្នកនិងគ្រួសាររបស់អ្នកទទួលបានការថែទាំដែលល្អបំផុត គ្រប់ទីកន្លែងដែលអ្នកទៅទទួលការថែទាំសុខភាពរបស់អ្នក។
- ត្រូវប្រាកដថា អ្នកនិងកូនរបស់អ្នកមិនខកខានការចាក់ថ្នាំណាមួយ ឬទទួលការចាក់ថ្នាំច្រើនពេក។
- អាចព្រីនកំណត់ត្រាសម្រាប់អ្នកឬកូនរបស់អ្នក នៅពេលអ្នកត្រូវការវា – ប្រសិនបើអ្នកផ្លាស់ប្តូរទីលំនៅ ប្រសិនបើគ្រូពេទ្យរបស់អ្នកចូលនិវត្តន៍ ឬនៅពេលកូនរបស់អ្នកចាប់ផ្តើមចូលរៀនឬបោះជំរុំ។
- គាំទ្រដល់ការទទួលបានសេវា តាមរយៈប្រព័ន្ធផលថលសម្រាប់អ្នកជំងឺនៃកំណត់ត្រា My Vax។ អ្នកជំងឺអាចស្នើសុំចូលទៅកាន់ព័ត៌មានអំពីការចាក់ថ្នាំបង្ការ និងប័ណ្ណសុខភាព SMART របស់ពួកគេ ពី MIIS តាមការចង់បាន។

### ហេតុអ្វីបានជាការណ៍នេះមានសារៈសំខាន់?

ដូចអ្នកដឹងហើយថា កាលវិភាគចាក់ថ្នាំដែលចាំបាច់ដើម្បីរក្សាបានសុខភាពល្អ អាចមានភាពស្មុគស្មាញបំផុត។ MIIS៖

- ជួយអ្នកឲ្យអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នក បន្តតាមដានថាតើការចាក់ថ្នាំមួយណាដែលដល់ពេលកំណត់ និងពេលណាដែលគួរទទួលបានការចាក់ថ្នាំ។
- រក្សាកំណត់ត្រាចាក់ថ្នាំបង្ការរបស់អ្នករួមគ្នាសម្រាប់អ្នក គ្រួសាររបស់អ្នក និងអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នក។
- ផ្តល់ភស្តុតាងបញ្ជាក់អំពីការចាក់វ៉ាក់សាំងសម្រាប់កូនអ្នក។
- ជួយបង្ការការផ្ទុះឡើងនៃជំងឺ ដូចជាកញ្ជ្រឹល និងគ្រុនផ្តាសាយធំនៅក្នុងសហាគមន៍។
- រក្សាកំណត់ត្រាចាក់ថ្នាំរបស់អ្នកឲ្យមានសុវត្ថិភាព នៅអំឡុងពេលគ្រោះមហន្តរាយធម្មជាតិ ដូចជាទឹកជំនន់ ឬព្យុះសង្ឃរា។

Immunize MA

## តើព័ត៌មានអ្វីខ្លះត្រូវបានរក្សាទុកនៅក្នុង MIIS?

- តារាងចាក់ថ្នាំដែលអ្នក ឬកូនរបស់អ្នកបានទទួល ក៏ដូចជាការចាក់ថ្នាំណាមួយដែលអ្នក ឬកូនរបស់អ្នកទទួលបាននាពេលអនាគត។
- ព័ត៌មានដែលចាំបាច់សម្រាប់ការចាក់ថ្នាំបង្ការដែលមានសុវត្ថិភាព និងត្រឹមត្រូវនៃអ្នកជំងឺនីមួយៗ ដូចជា៖
  - ឈ្មោះពេញ និងថ្ងៃខែឆ្នាំកំណើត។
  - ភេទ (ប្រុស ឬស្រី)។
  - ឈ្មោះមិនទាន់រៀបការរបស់ម្ដាយ (សម្រាប់កូន)។
  - អាសយដ្ឋាន និងលេខទូរសព្ទ។
  - ការិយាល័យអ្នកផ្ដល់សេវាដែលការចាក់ថ្នាំនីមួយៗត្រូវបានផ្ដល់ជូន។

## តើព័ត៌មាននេះចូលទៅក្នុងប្រព័ន្ធដោយរបៀបណា?

- ព័ត៌មានអំពីកុមារត្រូវបានបញ្ចូល នៅពេលកុមារម្នាក់កើតមក ឬនៅពេលកុមារម្នាក់ទទួលបានការចាក់ថ្នាំរបស់ពួកគេ។
- អ្នកផ្ដល់សេវាថែទាំសុខភាពរបស់អ្នកអាចបន្ថែមកំណត់ត្រារបស់អ្នក ឬកំណត់ត្រារបស់គ្រួសារអ្នក ប្រសិនបើកំណត់ត្រាមិនទាន់មាននៅក្នុង MIIS នៅឡើយ។

## តើនរណាខ្លះមានលទ្ធភាពចូលទៅកាន់កំណត់ត្រារបស់ខ្ញុំ?

- ក្រសួងសុខភាពសាធារណៈ (DPH) ប្រើប្រាស់បច្ចេកវិទ្យាទំនើបដើម្បីប្រាកដថារាល់ព័ត៌មានទាំងអស់ដែលបានបញ្ចូលទៅក្នុង MIIS ត្រូវបានរក្សាសុវត្ថិភាព និងការសម្ងាត់។
- ព័ត៌មាននៅក្នុង MIIS មានផ្ដល់ជូនតែចំពោះ៖
  - អ្នកផ្ដល់សេវាថែទាំសុខភាព ឬបុគ្គលផ្សេងទៀតដែលធាចំពោះការចាក់ថ្នាំបង្ការសមស្រប តាមដែល DPH បានអនុញ្ញាត។
  - សាលារៀន។
  - ក្រុមប្រឹក្សាសុខាភិបាលតាមមូលដ្ឋាន។
  - DPH រួមទាំងកម្មវិធី WIC និងទីភ្នាក់ងាររដ្ឋផ្សេងទៀត ឬកម្មវិធីដែលផ្ដល់ការអប់រំ និងការផ្សព្វផ្សាយអំពីការចាក់វ៉ាក់សាំងទៅដល់អតិថិជនរបស់ពួកគេ។
  - ផែនការសុខភាពសម្រាប់ការកែលម្អអត្រាចាក់ថ្នាំបង្ការ និងការប្រឹងប្រែងកែលម្អគុណភាពសម្រាប់ភាពជាដៃគូរបស់ផែនការនីមួយៗ។
  - ការសិក្សាដែលបានឯកភាពជាពិសេសដោយគណៈកម្មាធិការសុខភាពសាធារណៈដែលបំពេញតាមកិច្ចការពារផ្នែកច្បាប់យ៉ាងតឹងរឹង។

## តើមានអ្វីកើតឡើង បើព័ត៌មានរបស់ខ្ញុំត្រូវបានចែករំលែក?

- អ្នកមានសិទ្ធិកំណត់អ្នកដែលអាចមើលព័ត៌មានរបស់អ្នកបាន។
- ដើម្បីកំណត់អ្នកដែលអាចមើលព័ត៌មានរបស់អ្នកបាន អ្នកចាំបាច់ត្រូវបំពេញទម្រង់បែបបទ "ការបដិសេធ ឬការដកចេញពីការបដិសេធចំពោះការចែករំលែកទិន្នន័យ" ដែលអ្នកអាចទទួលបានពីអ្នកផ្ដល់សេវាថែទាំសុខភាពរបស់អ្នក។
- ប្រសិនបើអ្នកសម្រេចកំណត់អ្នកដែលអាចមើលព័ត៌មានរបស់អ្នក អ្នកផ្ដល់សេវាថែទាំសុខភាពបច្ចុប្បន្នរបស់អ្នកនឹងអាចមើលឃើញការចាក់ថ្នាំដែលបានផ្ដល់ជូនអ្នកនិងកូនរបស់អ្នក ប៉ុន្តែមិនអាចមើលឃើញប្រវត្តិការចាក់ថ្នាំបង្ការទាំងស្រុងរបស់អ្នកបានទេ។
- ប្រសិនបើអ្នកសម្រេចកំណត់អ្នកដែលអាចមើលឃើញព័ត៌មានរបស់អ្នក អ្នកនឹងមិនមានលទ្ធភាពទទួលបានរាល់អត្ថប្រយោជន៍ទាំងអស់របស់ MIIS ដូចជាការចែករំលែកកំណត់ត្រាចាក់ថ្នាំបង្ការរបស់អ្នកទៅកាន់សាលារៀននិងបន្ទប់សង្គ្រោះបន្ទាន់ និងកំណត់ត្រាចាក់ថ្នាំទាំងស្រុងរបស់អ្នកនៅក្នុងទីតាំងតែមួយឡើយ។
- អ្នកអាចផ្លាស់ប្ដូរចិត្តរបស់អ្នក (សម្រេចចែករំលែក ឬមិនចែករំលែកព័ត៌មានរបស់អ្នក) បានគ្រប់ពេល។

---

តើខ្ញុំអាចទទួលបានព័ត៌មានបន្ថែមដោយរបៀបណា?

សូមចូលទៅកាន់គេហទំព័រយើងតាមរយៈ: www.mass.gov/dph/miis, អ៊ីម៉ែលទៅកាន់ MyVaxRecords@mass.gov ឬសាកសួរអ្នកផ្ដល់សេវាថែទាំសុខភាពរបស់អ្នកសម្រាប់ព័ត៌មានបន្ថែម។